Seattle Department of Transportation

## នាយកដ្ឋានដឹកជញ្ជូនទីក្រុង Seattle (SDOT)

## សំណួរដែលសួរញឹកញាប់អំពី Transit Pass របស់ អាជ្ញាធរលំនៅឋានទីក្រុង Seattle (SHA) (2023)

1. **តើកម្មវិធីរបស់ក្រសួង SDOT Transit Pass របស់ អាជ្ញាធរលំនៅឋានទីក្រុង Seattle គឺជាអ្វី?**

   កម្មវិធីផ្តល់ប័ណ្ណធ្វើដំណើរ SHA Transit Pass របស់ ក្រសួង SDOT គឺជាប្រភេទកាត ORCA ដែលឧបត្ថម្ភពេញលេញសម្រាប់អ្នករស់នៅក្នុងគ្រប់លំនៅឋានទាំងអស់ ដែលកាន់កាប់ និងគ្រប់គ្រងដោយ SHA។ អ្នកចូលរួមក្នុងកម្មវិធីអាចធ្វើដំណើរដោយមិនគិតថ្លៃ គ្មានដែនកំណត់លើការធ្វើដំណើររហូតដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2026។

2. **តើអ្នកណាខ្លះមានសិទ្ធិទទួលបានប័ណ្ណធ្វើដំណើរកម្មវិធី SHA Transit Pass របស់ SDOT?**

   អ្នករស់នៅមណ្ឌល SHA ទាំងអស់ដែលមានអាយុចាប់ពី 19 ឆ្នាំឡើងទៅដែលរស់នៅក្នុងមណ្ឌលដែលជាកម្មសិទ្ធនិងទីតាំងដែលគ្រប់គ្រងដោយ SHA មានសិទ្ធិគ្រប់គ្រាន់ដើម្បីទទួលបានប័ណ្ណធ្វើដំណើរ SHA Transit Pass ។ មិនមានតម្រូវការយោលទៅតាមប្រាក់ចំណូលសម្រាប់ចូលរួមក្នុងកម្មវិធីនេះទេ។ <u>បុគ្គលត្រូវតែមានចុះឈ្មោះក្នុងបញ្ជីផ្ទះជួល ទើបមានសិទ្ធិទទួលបានកាត ORCA ។</u> សូមទាក់ទង SHA ប្រសិនបើបុគ្គលណាម្នាក់បច្ចុប្បន្នមិនមានឈ្មោះនៅក្នុងបញ្ជីជួលផ្ទះ ហើយត្រូវការចុះឈ្មោះ។

3. **តើទីតាំងណាខ្លះដែលមានសិទ្ធិទទួលសម្រាប់កម្មវិធីនេះ?**

   គ្រប់ទីតាំងរបស់ SHA កាន់កាប់និងគ្រប់គ្រងដោយ SHA ទាំង 99 កន្លែង មានសិទ្ធិទទួលសម្រាប់កម្មវិធីនេះ។ ទីតាំងដែលជាកម្មសិទ្ធ តែមិនគ្រប់គ្រងដោយ SHA មិនមានសិទ្ធិទទួលបានទេ។ បញ្ជីឈ្មោះនៃទីតាំងដែលមានសិទ្ធិទទួល អាចរកឃើញនៅលើគេហទំព័ររបស់យើង [www.seattle.gov/transportation/TransitPassProgram](http://www.seattle.gov/transportation/TransitPassProgram)។

4. **តើខ្ញុំអាចប្រើប័ណ្ណធ្វើដំណើរ SHA Transit Pass ថ្មីរបស់ខ្ញុំនៅឯណា?**

   ប័ណ្ណធ្វើដំណើរ SHA Transit Pass របស់ SDOT ត្រូវបានបញ្ចូលទៅក្នុងកាត ORCA ហើយ។ អ្នកអាចប្រើកាតដោយមិនគិតថ្លៃតាម King County Metro, King County Water Taxi, Seattle Streetcar, Seattle Center Monorail, Sound Transit, Community Transit, Pierce Transit, Kitsap Transit និង Everett Transit។ អ្នកក៏អាចប្រើកាត ORCA របស់អ្នកតាម ACCESS ឬ Via to Transit ។ កាត ORCA មិនអាចប្រើទៅលើសាឡាង Washington State Ferries បានទេ។

5. **ខ្ញុំរស់នៅក្នុងលំនៅឋានរបស់ SHA ដែលបានទទួលកាត ORCA រួចហើយ សម្រាប់កម្មវិធីនេះ។ តើខ្ញុំត្រូវដាក់ពាក្យសុំកាត ORCA ថ្មីទេ?**

   អ្នកមិនចាំបាច់ដាក់ពាក្យសុំកាត ORCA ថ្មីទេ។
   កាតបច្ចុប្បន្នទាំងអស់ត្រូវបានបន្តនិងមានសុពលភាពរហូតដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2026។
   អ្នកអាចបន្តប្រើកាត ORCA របស់អ្នកដដែល។ យើងលើកទឹកចិត្តឱ្យអ្នកបន្តចូលរួមទាំងអស់-
   អោយបំពេញការស្ទង់មតិរបស់យើង
   ដើម្បីឱ្យយើងដឹងពីរបៀបដែលកម្មវិធីកំពុងដំណើរការចំពោះអ្នកតាមរយៈតំណភ្ជាប់នេះ៖
   www.surveymonkey.com/r/SHAIntakeForm ។ ការស្ទង់មតិនេះមានច្រើនភាសា
   ហើយអាចចូលប្រើបានតាមតំណនេះ៖ www.seattle.gov/transportation/TransitPassProgram

6. **តើខ្ញុំធ្វើម្តេចបានខ្ញុំដឹងថា ខ្ញុំមានកាត ORCA រួចហើយតាមរយៈកម្មវិធីនេះ?**

   កាត ORCA ទាំងអស់ដែលបានចែកចាយតាមរយៈកម្មវិធីនេះមាននិមិត្តសញ្ញា SHA
   នៅខាងក្រោយកាត។ ប្រសិនបើអ្នកមិនប្រាកដទេ អ្នកអាចទាក់ទង SDOT
   ហើយយើងអាចបញ្ជាក់ព័ត៌មានរបស់អ្នក។

7. **តើកម្មវិធី SHA Transit Pass របស់ SDOT ដែលត្រូវបានពង្រីកនឹងចាប់ផ្តើមនៅពេលណា?**

   ការពង្រីកកម្មវិធីនឹងចាប់ផ្តើមនៅខែមករា ឆ្នាំ 2023 ជាមួយនឹងការចែកចាយកាតចាប់ពីថ្ងៃទី 24
   ខែមករា ឆ្នាំ 2023។

8. **តើកម្មវិធីត្រូវបានផ្តល់មូលនិធិយ៉ាងដូចម្តេច?**

   កម្មវិធីនេះត្រូវបានផ្តល់មូលនិធិតាមរយៈវិធានការដឹកជញ្ជូនទីក្រុង Seattle (STM)
   ដែលពីមុនត្រូវបានគេស្គាល់ថាជាតំបន់អត្ថប្រយោជន៍ដឹកជញ្ជូន Seattle (STBD)។ STM
   គឺជាពន្ធលក់ដូរដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោត
   ដែលថ្មីៗនេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោតក្នុងខែវិច្ឆិកា ឆ្នាំ 2020 និងផុតកំណត់នៅខែមេសា
   ឆ្នាំ 2027។

9. **តើខ្ញុំអាចទទួលបាន SDOT & SHA Transit Pass ថ្មីរបស់ខ្ញុំដោយរបៀបណា?**

   អ្នកជួលកន្លែងរស់នៅតាមលំនៅឋានដែលមានសិទ្ធិទទួល
   នឹងទទួលបានការជូនដំណឹងអំពីកម្មវិធីតាមរយៈសំបុត្រនៅខែមករា ឆ្នាំ 2023

អញ្ជើញសមាជិកនីមួយៗដែលមានចំណាប់អារម្មណ៍និងសមាជិនៃក្រុមគ្រួសារដែលមានសិទ្ធិទទួល ឱ្យមកបំពេញក្រដាសពាក្យសុំជំនួយពី SHA ។ ក្រដាសនេះមាននៅតាមអ៊ីនធឺណិតជាភាសា អង់គ្លេស អាហារិក អារ៉ាប់ ចិន (អក្សរកាត់) ចិន (អក្សរពេញតួ) អង់គ្លេស ខ្មែរ កូរ៉េ អូរ៉ូម៉ូ រុស្ស៊ី សូម៉ាលី អេស្ប៉ាញ តាកាឡុក ទីគ្រីយ៉ា និងវៀតណាមនៅលើគេហទំព័ររបស់យើង៖ [www.seattle.gov/transportation/TransitPassProgram](http://www.seattle.gov/transportation/TransitPassProgram)។

សូមរំឭក មានតែបុគ្គលដែលបានចុះបញ្ជីនៅលើក្រដាសជួលកន្លែងរស់នៅប៉ុណ្ណោះ ទើបមានសិទ្ធិទទួលបានកាតនេះ។

កាតនោះនឹងត្រូវបានចែកចាយនៅក្នុងព្រឹត្តិការណ៍ផ្សេងៗដោយផ្ទាល់រវាងខែមករាដល់ខែមីនាឆ្នាំ 2023។ ទីតាំងចែកចាយនឹងអាចទៅដល់បានតាមរយៈឡានក្រុង ហើយមានទីតាំងនៅឬនៅជិតលំនៅឋានរបស់ SHA ។ បុគ្គលទាំងអស់ដែលទទួលបានកាត ចាំបាច់ត្រូវមានអ្វីមួយដែលមានឈ្មោះរបស់ពួកគេនៅលើនោះ វាមិនចាំបាច់ជាឯកសារផ្លូវការទេ។ វាគ្រាន់តែបញ្ជាក់ថាឈ្មោះរបស់អ្នកសរសេរបានត្រឹមត្រូវប៉ុណ្ណោះ។

ស្វែងយល់បន្ថែមអំពីទីតាំងចែកចាយ និងកាលបរិច្ឆេទនៅលើគេហទំព័ររបស់យើង [www.seattle.gov/transportation/TransitPassProgram](http://www.seattle.gov/transportation/TransitPassProgram)។

### 10. ខ្ញុំមិនអាចចូលរួមព្រឹត្តិការណ៍ចែកចាយដោយផ្ទាល់បានទេ។ តើខ្ញុំអាចទទួលបានកាត ORCA យ៉ាងដូចម្តេច?

អាចអោយនរណាម្នាក់យកកាតជំនួសអ្នក ប៉ុន្តែទាល់តែអ្នកបានចុះឈ្មោះជាមុនដោយប្រើក្រដាសបំពេញរបស់ SHA តែប៉ុណ្ណោះ។ អ្នកអាចចូលយកក្រដាសបំពេញនោះនៅទីនេះ៖[www.seattle.gov/transportation/TransitPassProgram](http://www.seattle.gov/transportation/TransitPassProgram)។ អ្នកដែលមកទទួលយកកាតរបស់អ្នក ក៏នឹងត្រូវការមានអ្វីមួយដែលមានឈ្មោះរបស់អ្នកនៅលើនោះ នេះអាចជាប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណម្យ៉ាង ក្រដាសជួលផ្ទះ ឬសំបុត្រមួយច្បាប់។ វាមិនចាំបាច់ជាឯកសារផ្លូវការទេ។ វាគ្រាន់តែដើម្បីបញ្ជាក់ថា ឈ្មោះរបស់អ្នក សរសេរបានត្រឹមត្រូវ។

ក្នុងករណីដែលគ្មាននរណាម្នាក់អាចមកទទួលយកកាតជំនួសអ្នកបាន ប្រសិនបើអ្នកបានបំពេញក្រដាសសុំជំនួយពី SHA តាមអ៊ីនធឺណិត ហើយមានសិទ្ធិទទួលជំនួយពីកម្មវិធីនេះ យើងនឹងផ្ញើកាតឱ្យអ្នកនៅចុងនិទាឃរដូវឆ្នាំ 2023។

### 11. ទៅពេលអនាគត តើប្រជាជនដែលប្រាក់ចំណូលទាបរស់នៅតាមលំនៅឋានឯទៀត (ដូចជាអ្នកកាន់ប័ណ្ណ section 8) នឹងមានសិទ្ធិទទួលជំនួយពី SHA Transit Pass របស់ SDOT ដែរឬទេ?

ពេញមួយកម្មវិធីនេះ នាយកដ្ឋានដឹកជញ្ជូន និងអាជ្ញាធរលំនៅឋាន Seattle នឹងធ្វើការរួមគ្នាដើម្បីវាយតម្លៃកម្មវិធី។ លទ្ធផលនៃការវាយតម្លៃ មតិកែលម្អពីសាធារណៈជន ហើយនិងការមានផ្តល់មូលនិធិនឹងជួយកែលម្អកម្មវិធីនាពេលឆ្នាំនៅខាងមុខ។

## 12. តើខ្ញុំអាចជំនួសកាត ORCA ដែលបាត់បង់/ខូចដោយរបៀបណា?

ប្រសិនបើកាត ORCA របស់អ្នកបាត់ ឬខូច យើងនឹងអោយវាវិញដោយមិនគិតថ្លៃ។ សូមទាក់ទង SHA ដោយប្រើឈ្មោះ និងអាសយដ្ឋានរបស់អ្នក ដើម្បីស្នើសុំកាតថ្មីវិញ។ កាតចាស់របស់អ្នកនឹងត្រូវបិទចោល នៅពេលអ្នកត្រូវបានគេចេញកាតថ្មីឱ្យ។

## 13. ប្រសិនបើខ្ញុំមានសំណួរបន្ថែម តើខ្ញុំគួរទាក់ទងអ្នកណា?

ព័ត៌មានអំពីកម្មវិធីនេះក៏មាននៅលើគេហទំព័ររបស់ SDOT គឺ www.seattle.gov/transportation/TransitPassProgram ។

***SHA***

ទូរស័ព្ទ (ហៅ): (206) 615-3551

អ៊ីមែល: TransitPass@seattlehousing.org